国家级教学成果二等奖系列教材

亚非语言文学国家级特色专业建设点系列教材

សៀវភៅអំណានភាសាខ្មែរ

# 柬埔寨语阅读教程(1)

卢　军◎编著



世界图书出版公司

国家级教学成果二等奖系列教材

亚非语言文学国家级特色专业建设点系列教材

សៀវភៅអំណានភាសាខ្មែរ

# 柬埔寨语阅读教程(1)

卢　军◎编著



世界图书出版公司

广州·上海·西安·北京

图书在版编目（CIP）数据

柬埔寨语阅读教程. 1 / 卢军编著. —广州：世界图书出版广东有限公司，2017.3

ISBN 978-7-5192-2481-3

Ⅰ. ①柬… Ⅱ. ①卢… Ⅲ. ①柬埔寨语—阅读教学—教材 Ⅳ. ①H613.94

中国版本图书馆CIP数据核字（2017）第050392号

| | |
|---|---|
| 书　　名 | 柬埔寨语阅读教程（1）<br>JIANPUZHAI YUEDU JIAOCHENG (1) |
| 编 著 者 | 卢　军 |
| 策划编辑 | 刘正武 |
| 责任编辑 | 张梦婕 |
| 装帧设计 | 吴伟边 |
| 出版发行 | 世界图书出版广东有限公司 |
| 地　　址 | 广州市新港西路大江冲25号 |
| 邮　　编 | 510300 |
| 电　　话 | 020-84451969　84453623　84184026　84459579 |
| 网　　址 | http://www.gdst.com.cn |
| 邮　　箱 | pub@gdst.com.cn |
| 经　　销 | 各地新华书店 |
| 印　　刷 | 广州市德佳彩色印刷有限公司 |
| 开　　本 | 787mm × 1092mm　1/16 |
| 印　　张 | 11.75 |
| 字　　数 | 250千 |
| 版　　次 | 2017年3月第1版　2017年3月第1次印刷 |
| 国际书号 | ISBN 978-7-5192-2481-3 |
| 定　　价 | 38.00元 |

版权所有　侵权必究
（如有印装错误，请与出版社联系）

此为试读，需要完整PDF请访问：www.ertongbook.com

# 编者的话

《柬埔寨语阅读教程》系中国非通用语教学研究会会长、解放军外国语学院亚非语系主任、博士生导师钟智翔教授主持的国家级教学成果二等奖系列教材之一，也是国家外语非通用语种本科人才培养基地暨亚非语言文学国家级特色专业建设点建设教材。

本教材是解放军外国语学院柬埔寨语专业自1998年成立以来，在使用多年的阅读课教材的基础上，结合人才培养新需求，编写出的一本适合21世纪柬埔寨语教育特点的新教材。本教材可作为柬埔寨语阅读课程的配套教材使用。我们希望通过对本教材的学习，可以使学生扩大阅读范围，提高阅读兴趣，掌握阅读技巧，增强理解水平，提高阅读能力，加深对柬埔寨语言和文化的了解。

《柬埔寨语阅读教程》的课文均选自柬埔寨语原文材料，内容丰富，形式多样，反映了柬埔寨语的特点和柬埔寨文化的面貌。题材上既包括日常生活、文化习俗等内容，也包括社会、历史、地理等国情知识。体裁上既包含记叙文、说明文，也包含议论文、应用文等各种文体。难度上循序渐进，由浅入深。

《柬埔寨语阅读教程》第一册共15课，每课包括课文、词汇、注释、练习、副课、副课练习、补充阅读材料等部分，教材后还附有词汇总表。本教材适合二年级上学期的阅读课程使用，教学用时为30学时，教师可根据实际教学情况适当调整。

《柬埔寨语阅读教程》在编写过程中，得到了解放军外国语学院亚非语系教材建设委员会、解放军外国语学院亚非语言文学二级学科博士学位授权点，以及中国出版集团世界图书出版广东有限公司的大力支持，谨在此一并表示衷心的感谢！

由于编者水平有限，书中难免出现不妥和疏漏之处，恳请学界专家、诸位同仁及使用者不吝批评指正。

编　者

2017年1月1日

于解放军外国语学院

# 目 录


មេរៀនទី ១ ប្រយោជន៍នៃអំនានសៀវភៅ ······ 1

ចូរថែរក្សាសៀវភៅរបស់អ្នក ······ 5

វិធីអានផ្សេងៗ ······ 7

មេរៀនទី ២ សិស្សជាប់ចំណាត់ថ្នាក់ក្រោយគេ ······ 10

ការរៀបរាប់ពីគុណសម្បត្តិរបស់មិត្ត ······ 14

សន្ទនារវាងនិស្សិតពីរនាក់ ······ 17

មេរៀនទី ៣ ការប្រើវចនានុក្រម ······ 19

សម្ដេចព្រះសង្ឃរាជ ជួន ណាត ······ 24

រូបមន្តនៃការរៀន ······ 26

មេរៀនទី ៤ ផែនការរៀននៅមហាវិទ្យាល័យ ៤ ឆ្នាំ ······ 29

ហេតុអ្វីបានជាយើងត្រូវរៀន ······ 34

គោលដៅនៅក្នុងការសិក្សា ······ 37

មេរៀនទី ៥ ព្រលឹងជាតិខ្មែរ ······ 41

កម្ពុជាមាតុភូមិជាទីស្នេហា ······ 46

នគររាជ ······ 49

មេរៀនទី ៦ ការងារប្រចាំថ្ងៃ ······ 51

កំណាប់ឪពុកខ្ញុំ ······ 57

តំលៃពលកម្ម ······ 60

មេរៀនទី ៧ ការគោរពឱនលំទោន ······ 62

សុជីវធម៌ ······ 67

អំពីការសំពះ ······ 70

មេរៀនទី ៨ សំបុត្រសួរសុខទុក្ខមិត្តភក្តិ ··· 72
ជំនឿជាក់លើខ្លួនឯង ··· 76
រឿងកុំគ្រាប់តាមបង ··· 80

មេរៀនទី ៩ ការជ្រើសរើសម៉ូតសំលៀកបំពាក់ ··· 83
របៀបស្លៀកពាក់ ··· 89
ក្រមាខ្មែរ ··· 92

មេរៀនទី ១០ អាហារសម្រាប់បរិភោគរាល់ថ្ងៃ ··· 94
របៀបបរិភោគអាហារក្នុងគ្រួសារ ··· 99
ម្ហូបឆ្ងាញ់ៗខ្មែរ ··· 102

មេរៀនទី ១១ ចំណេះដឹងអំពីផ្ទះខ្មែរ ··· 105
កំណាព្យ ផ្ទះខ្មែរ ··· 110
ផ្ទះកូនកម្លោះនៃប្រពៃណីជនជាតិចារាយ ··· 114

មេរៀនទី ១២ ការរក្សាសុវត្ថិភាពនៅពេលដើរនិងពេលជិះកង់ ··· 117
គមនាគមន៍កម្ពុជា ··· 121
ប្រវត្តិផ្លូវដែកកម្ពុជា ··· 125

មេរៀនទី ១៣ វិស្សមកាលលើបឹងទន្លេសាប ··· 128
អំពីបឹងទន្លេសាប ··· 133
រឿងវាសនាបឹងទន្លេសាប ··· 136

មេរៀនទី ១៤ ប្រយោជន៍នៃទេសចរណ៍ ··· 138
វិធានការការពារអង្គរវត្ត ··· 142
វិស័យទេសចរណ៍កម្ពុជា ··· 145

មេរៀនទី ១៥ បុណ្យភ្ជុំបិណ្ឌ ··· 148
ពិធីបុណ្យប្រពៃណីជាតិ ··· 153
ប្រភពពិធីបុណ្យប្រណាំងទូក ··· 157

បញ្ជីពាក្យថ្មី ··· 160

# មេរៀនទី ១

ចេះពីរៀន មានពីរក ក្រពីខ្ជិល

## អត្ថបទសំខាន់

### ប្រយោជន៍នៃអំនានសៀវភៅ



អំនានសៀវភៅ នាំឱ្យអ្នកមានចំណេះដឹងច្រើន។ អ្នកអានសៀវភៅដើម្បីដឹងពត៌មានផ្សេងៗអំពីវិទ្យាសាស្ត្រ ភាសា ប្រវត្តិវិទ្យា ភូមិវិទ្យា គណិតវិទ្យា និងមុខវិជ្ជាដទៃទៀតជាច្រើន។ តាមរយៈអំនានសៀវភៅ អ្នកបានយល់អំពីការរស់នៅរបស់ប្រជាជនក្នុងប្រទេស និងក្នុងតំបន់ ដទៃទៀត នៅលើពិភពលោក។ ទន្ទឹមនឹងនេះអ្នកអាចរៀនសូត្រសីលធម៌ល្អ សប្បុរសធម៌ និង អាកប្បកិរិយាល្អរបស់មនុស្សដែលមានគុណធម៌ខ្ពស់។ លើសពីនេះទៅទៀត អ្នកត្រងត្រាប់ បានពាក្យពេចន៍ ឬ គំនិតល្អៗជាច្រើន និងសិល្បវិធីប្លែកៗរបស់អ្នកនិពន្ធ។

អំនានសៀវភៅ មិនត្រឹមតែផ្តល់ការយល់ដឹងដល់អ្នកប៉ុននោះទេ ថែមទាំងផ្តល់ការសប្បាយរីករាយដល់អ្នកទៀត ព្រោះអ្នកបានឃើញរូបភាពល្អៗ ប្លែកៗជាច្រើននៅក្នុងសៀវ ភៅ។ ម្យ៉ាងទៀត នៅពេលអានសៀវភៅ អ្នកហាក់ដូចជាបានធ្វើដំណើរទៅដល់កន្លែងដែល អ្នកនិពន្ធបានរៀបរាប់នៅក្នុងអត្ថបទនោះ។ អំនានសៀវភៅធ្វើឱ្យអ្នកមានជំនាក់ចិត្ត និងអាចបំបាត់ការអផ្សុកបាន។ ការទទួលយកខ្លឹមសារ ស្វែងយល់ពីរឿងរ៉ាវ ឬទទួលបានការ

កម្សាន្តរីករាយត្រូវតាមគោលបំណងរបស់អ្នកសរសេរ គឺជាការអានដ៏ត្រឹមត្រូវនិងទទួលបានប្រយោជន៍ពិតប្រាកដ។

កវី អ្នកនិពន្ធខ្មែរសម័យបុរាណ បានបន្សល់ទុកស្នាដៃអក្សរសិល្ប៍ជាច្រើនដល់កូនចៅជំនាន់ក្រោយ សម្រាប់អានកំសាន្តនិងអប់រំ។ ក្នុងនោះ រឿងខ្លះជារឿងបែបប្រលោមលោកបុរាណសរសេរជាពាក្យកាព្យ ដូចជារឿងកាកី ទុំទាវ...។ រឿងខ្លះទៀតជារឿងបែបប្រលោមលោកសម័យ សរសេរជាពាក្យរាយ ដូចជា រឿងផ្កាស្រពោន កុលាបប៉ៃលិន...។ កវីនិពន្ធតាក់តែងឃ្លាឃ្លោងពីរោះរណ្ដំធ្វើឱ្យអ្នកអាន អ្នកស្ដាប់ជក់ចិត្តតាមដំណើររឿង។ ជួនកាលធ្វើឱ្យពួកគាត់ខឹងនឹងតួអង្គកាច ស្រឡាញ់អាណិតតួអង្គស្លូត។ រឿងខ្លះមានដំណើររឿងវែង តែស្ដាប់ទៅជក់ចិត្ត អាចបំបាត់ការអផ្សុកបាន។ រឿងខ្លះកំប្លែងខ្លី តែមានន័យអប់រំល្អ ធ្វើឱ្យអ្នកស្ដាប់ អ្នកអានផ្ទុះសំណើចរសាយទុក្ខព្រួយបានមួយដងមួយគ្រា។

ក្រៅពីស្នាដៃដែលមានឈ្មោះអ្នកនិពន្ធនិងកាលបរិច្ឆេទរឿងត្រឹមត្រូវ នៅមានរឿងខ្លះទៀត ដែលគេចេះចាំតៗគ្នា ពុំមានឈ្មោះអ្នកនិពន្ធនិងកាលបរិច្ឆេទត្រឹមត្រូវឡើយ។ យើងតែងហៅថា អក្សរសិល្ប៍ប្រជាប្រិយ។ អក្សរសិល្ប៍ប្រជាប្រិយជា អត្ថបទរឿងខ្លីនិយាយទាក់ទងនឹងប្រវត្តិសាស្ត្រ ទំនៀមទម្លាប់ ប្រពៃណី ជីវភាពប្រជាជន ហើយអប់រំប្រជាពលរដ្ឋយើងកុំឱ្យប្រព្រឹត្តអំពើអាក្រក់ កុំឱ្យមានចិត្តនិន្នាឈ្នានីសចេះស្រឡាញ់ រួមកម្លាំងគ្នាកសាងគ្រួសារនិងសង្គមជាតិឱ្យរីកចម្រើនជានិច្ច។

## ពាក្យថ្មី

| | | | |
|---|---|---|---|
| ប្រយោជន៍ | [梵; 巴] | *ន.* | 利益，好处 |
| ពត៌មាន | [梵; 巴] | *ន.* | 信息，新闻 |
| វិទ្យាសាស្ត្រ | [梵] | *ន.* | 科学 |
| ប្រវត្តិវិទ្យា | [巴; 梵] | *ន.* | 历史 |
| ភូមិវិទ្យា | [梵] | *ន.* | 地理学 |
| គណិតវិទ្យា | [梵] | *ន.* | 数学 |
| អំនាន | [高] | *ន.* | 阅读 |

| | | | |
|---|---|---|---|
| ពិភពលោក | [梵；巴] | ន. | 世界 |
| ទន្ទឹមនឹងនេះ | | | 与此同时 |
| សីលធម៌ | [巴；梵] | ន. | 道德，品行 |
| អាកប្បកិរិយា | [巴；梵] | ន. | 态度，姿态 |
| ខ្ពស់ | [高] | គុ. | 高的 |
| ពេចន៍ | [梵；巴] | ន. | 语言，词语 |
| ប៉ុន | [高] | គុ. | 同样的，相同的 |
| រូបភាព | [梵；巴] | ន. | 照片，图片 |
| ប្លែក | [高] | គុ. | 不同的，奇异的 |
| ម្យ៉ាង | [高] | ន. | 一样，一种 |
| ហាក់ដូចជា | | | 好像，类似 |
| អត្ថបទ | [巴；梵] | ន. | 文章，论文 |
| ជំនាក់ | [高] | ន. | 信任，相信 |

## សេចក្ដីពន្យល់

1 石碑文学是柬埔寨最早的文学形式。柬埔寨的碑铭多是吴哥王朝时期的遗存。古代高棉的诗人们喜欢把自己的诗作雕刻在石碑上，因此称为“石碑文学”。柬埔寨石碑文学的内容大多是关于王朝历史的变迁，帝王的言论、功绩，战争的过程，佛事功德，以及对修建庙宇佛殿的记载等。

2 在柬埔寨漫长的历史长河中，广大劳动人民也创作了不少文学作品，特别是口传文学。但是由于缺少文字记载，这些作品的具体数量无法说清。柬埔寨1953年独立后，王国政府组织专家学者在全国范围内进行深入的民间文学调查，陆续整理出版了一批有价值的民间文学作品。

3 柬埔寨语部分词汇的词性可按规律进行变化，如动词→名词，形容词→名词，动词→使动词。如名词អំនាន（阅读，读书）是动词អាន（读书，阅读）的派生词；名词

ចំណេះ（知识）是动词ចេះ（懂，会）的派生词。

4 动词ឱ្យ（给，给予；使，指使）在柬埔寨语各种书籍、报刊、杂志及网络媒体中有几种常见形式，如អោយ，ឲ្យ，ឱយ等，在网络媒体中因输入方便最常用的是ឲ្យ，柬埔寨尊那僧王编写的《高棉大辞典》中正式的书写形式是ឱ្យ，本教程中统一使用ឱ្យ。

## លំហាត់

**1. 选择题**

(1) តាមរយៈការអានសៀវភៅ យើងអាចទទួលចំណេះដឹងនៅវិស័យណាខ្លះ? ( )

A. វិទ្យាសាស្ត្រ　　B. ភូមិវិទ្យា

C. គណិតវិទ្យា　　D. ភាសា

E. ប្រវត្តិវិទ្យា　　F. ចំណេះធ្វើ

(2) ការរៀបរាប់នៅខាងក្រោមនេះ តើប្រការណាមិនត្រឹមត្រូវ? ( )

A. ពេលអានសៀវភៅ អ្នកហាក់ដូចជាបានធ្វើដំណើរទៅដល់កន្លែង ដែលអ្នកនិពន្ធបានរៀបរាប់

B. អំនានសៀវភៅថែមទាំងផ្តល់ការសប្បាយរីករាយដល់អ្នកអាន

C. អំនានសៀវភៅមិនអាចធ្វើឱ្យអ្នកបំបាត់ការអផ្សុកបាន

D. តាមរយៈអំនានសៀវភៅ អ្នកបានយល់អំពីការរស់នៅរបស់ប្រជាជនក្នុងប្រទេសនិងក្រៅប្រទេស

(3) តើប្រលោមលោក *កុលាបប៉ៃលិន* ជាស្នាដៃអក្សរសិល្ប៍បែបណា? ( )

A. ពាក្យកាព្យ　　B. ពាក្យរាយ

C. រឿងព្រេង　　D. រឿងកំប្លែង

**2. 填空题**

(1) ________ អ្នកអាចរៀនសូត្រសីលធម៌ល្អ សប្បុរសធម៌ និងអាកប្បកិរិយាល្អរបស់មនុស្សដែលមានគុណធម៌ខ្ពស់។

(2) ម្យ៉ាងទៀត នៅពេលអានសៀវភៅ អ្នក________បានធ្វើដំណើរទៅដល់កន្លែង ដែលអ្នកនិពន្ធបានរៀបរាប់នៅក្នុងអត្ថបទនោះ។



此为试读，需要完整PDF请访问：www.ertongbook.com

(3) កវី អ្នកនិពន្ធខ្មែរ ____________ បានបន្សល់ទុកស្នាដៃអក្សរសិល្ប៍ជាច្រើនដល់កូនចៅជំនាន់ក្រោយ សម្រាប់អានកំសាន្តនិងអប់រំ។

**3. 问答与思考题**

(1) តាមអត្ថបទខាងលើ អ្នកយល់ថា តើអំនានសៀវភៅមានប្រយោជន៍អ្វីខ្លះ?

(2) ចូររៀបរាប់ថា តើអ្នកទទួលប្រយោជន៍អ្វីពីអំនានសៀវភៅ?

(3) តើអ្នកធ្លាប់អានសៀវភៅណាខ្លះ ហើយចូលចិត្តសៀវភៅណាជាងគេ?

(4) តើអ្នកចូលចិត្តមើលសៀវភៅអេឡិចត្រូនិចឬសៀវភៅធម្មតា?ហេតុអ្វី?

## អត្ថបទអំនាន

# ចូរថែរក្សាសៀវភៅរបស់អ្នក

សូមអ្នក ៖

១. ដាក់ក្របសៀវភៅរបស់អ្នកដោយប្លាស្ទិក ឬក្រដាស(ក្រដាសកាសែតឬទស្សនាវដ្ដីក៏អាចប្រើបានដែរ)។

២. សំអាតដៃរបស់អ្នកឱ្យបានស្អាត មុនពេលចាប់កាន់ឬបើកទំព័រសៀវភៅ។

៣. នៅពេលប្រើប្រាស់សៀវភៅថ្មីជាលើកដំបូង សូមដាក់សៀវភៅផ្ដេកជាមុន រួចបើកមួយពីរឬបីទំព័រសិន។ នៅពេលបើកទំព័រសៀវភៅ សូមសង្កេតមើលគល់សន្លឹកសៀវភៅផង។ បើមានរបើក ឬរបេះចេញ សូមរកការបិទវាវិញយ៉ាងប្រុងប្រយ័ត្ន។

៤. ប្រើក្រដាសមួយសន្លឹក ដើម្បីសៀតសំគាល់ទំព័រក្នុងសៀវភៅ។

៥. បិទទំព័រសៀវភៅដែលរហែកឱ្យបានភ្លាមៗ។

៦. កាន់សៀវភៅដោយប្រុងប្រយ័ត្ននៅពេលហុចពីមនុស្សម្នាក់ទៅម្នាក់ទៀត។

៧. ទុកសៀវភៅនៅកន្លែងស្ងួតស្អាតជានិច្ច។

៨. នៅពេលអ្នកបាត់សៀវភៅ សូមជំរាបលោកគ្រូ អ្នកគ្រូភ្លាម។

សូមអ្នក ៖

១. កុំបត់ទំព័រសៀវភៅ។

២. កុំសរសេរនៅលើក្រប ឬទំព័រសៀវភៅ។

៣. កុំកាត់រូបភាពចេញពីសៀវភៅ។

៤. កុំហែក ឬផ្តាច់ទំព័រណាមួយចេញពីសៀវភៅ។

៥. កុំបើកចំហសៀវភៅ ឬផ្កាប់ទុកចោលនៅពេលមិនប្រើប្រាស់។

៦. កុំប្រើខ្មៅដៃ ប៊ិច ឬវត្ថុក្រាស់ៗទៅសៀតសំគាល់ទំព័រក្នុងសៀវភៅ។

៧. កុំបង្ខំញាត់សៀវភៅទៅក្នុងសំពៀតដែលមានរបស់របរពេញហើយ។

៨. កុំយកសៀវភៅទូលបាំងថ្ងៃ ឬភ្លៀង ហើយអង្គុយលើសៀវភៅ។

## ពាក្យថ្មី

| | | | |
|---|---|---|---|
| ប្លាស្ទិក | [法] | *ន.* | 塑料 |
| ក្រដាស | [高] | *ន.* | 纸，纸张 |
| កាន់ | [高] | *កិ.* | 持，拿 |
| សង្កេត | [梵；巴] | *កិ.* | 观察，检查 |
| សន្លឹក | [高] | *សំ.នុ.* | 页，张，片 |
| របើក | [高] | *កិ.* | 裂开，敞开 |
| របេះ | [高] | *កិ.* | 脱落，裂开 |
| កាវ | [汉] | *ន.* | 胶，胶水 |
| សៀត | [高] | *កិ.* | 掖，插 |
| ផ្កាប់ | [高] | *កិ.* | 反扣，倒扣；翻转 |

## លំហាត់

**1.** 判断题

(1) យើងអាចដាក់ក្រុបសៀវភៅរបស់ខ្លួនដោយក្រដាសសៀវភៅបាន។ (　　)

(2) ដើម្បីថែរក្សាសៀវភៅ យើងត្រូវសំអាតដៃរបស់អ្នកឱ្យបានស្អាត។ ( )

(3) ពាក្យ " បិទ " ក្នុងឃ្លា " សូមរកការបិទវាវិញ " មានន័យផ្ទុយនឹងពាក្យ " បើក " ក្នុងឃ្លា " បើកទំព័រសៀវភៅ " ។ ( )

(4) បើសិនអ្នកបាត់សៀវភៅ ត្រូវតែជំរាបលោកគ្រូ អ្នកគ្រូភ្លាម។ ( )

(5) បើសិនយើងចូលចិត្តរូបភាពណាមួយក្នុងសៀវភៅ យើងអាចកាត់វាចេញ។ ( )

**2.** 翻译题

(1) ដាក់ក្របសៀវភៅរបស់អ្នកដោយប្លាស្ទិក ឬក្រដាស(ក្រដាសកាសែត ឬទស្សនាវដ្ដីក៏អាចប្រើបានដែរ)។

(2) កាន់សៀវភៅដោយប្រុងប្រយ័ត្ននៅពេលហុចពីមនុស្សម្នាក់ទៅម្នាក់ទៀត។

(3) កុំបង្ខំញាត់សៀវភៅទៅក្នុងសំពៀតដែលមានរបស់របរពេញហើយ។

**3.** 问答与思考题

(1) ហេតុអ្វីបានជាយើងត្រូវថែរក្សាសៀវភៅ?

(2) ដើម្បីថែរក្សាសៀវភៅ យើងត្រូវធ្វើយ៉ាងដូចម្ដេច ហើយមិនត្រូវធ្វើយ៉ាងដូចម្ដេច?

(3) ពេលធម្មតា តើអ្នកថែរក្សាសៀវភៅរបស់ខ្លួនយ៉ាងដូចម្ដេច?

**4.** 请用柬埔寨语复述课文大意。

## អត្ថបទបន្ថែម

# វិធីអានផ្សេងៗ

ការអាន គឺការស្វែងយល់ពីអត្ថន័យដែល សរសេរ ដោយខ្លួនឯងនិងអ្នកដទៃរួមទាំងការស្វែងយល់ពីអត្ថន័យ តាមសញ្ញាសម្គាល់ និង និមិត្តសញ្ញា ផ្សេងៗដូចជា និមិត្តសញ្ញាចរាចរ ឬជាសញ្ញាសម្គាល់លើផែនទី ជាដើម។

ការទទួលយកខ្លឹមសារ ស្វែងយល់ពីរឿងរ៉ាវ ឬទទួលបានការកម្សាន្តរីករាយត្រូវតាមគោលបំណងរបស់អ្នកសរសេរ គឺជាការអានដ៏ត្រឹមត្រូវនិងទទួលបានប្រយោជន៍ពិតប្រាកដ។

ការអានមានច្រើនកម្រិត និងមានវិធីផ្សេងៗទៅតាមគោលដៅរបស់អ្នកអាននិងទៅតាមប្រភេទអត្ថបទ។ ការអានដើម្បីសិក្សាស្រាវជ្រាវ និងសរសេរអត្ថបទ អាចប្រើវិធីផ្សេងៗដូចខាងក្រោម ៖

១. អានពិនិត្យមើល  អានសេចក្ដីក្នុងសៀវភៅយ៉ាងលឿនដើម្បីស្វែងយល់ពីលក្ខណៈរួមនៃអត្ថបទនិពន្ធ សំនួននៃការប្រើភាសា គោលដៅនៃសំណេរ...ដែលជាវិធីអានដ៏មានសារៈប្រយោជន៍ជាខ្លាំងក្នុងការជ្រើសរើសសៀវភៅអាន ដើម្បីឱ្យត្រូវនឹងវត្ថុបំណងតាមកម្រិតដែលយើងចង់បាន។

២. អានចោះៗ ជាវិធីអាន  ដើម្បីស្វែងយល់ពីខ្លឹមសារទូទៅនៃអត្ថបទ  ដោយជ្រើសអានទៅលើសេចក្ដីមួយចំនួនដូចជា  អានអារម្ភកថា មាតិកា ខ្លឹមសារសង្ខេប ខ្លឹមសារសរុបនិងអានទៅលើខ្លឹមសារណា ដែលយើងចង់ដឹងប៉ុណ្ណោះ។

៣. អានត្រួសៗ  ជាការអានបែបមើលមួយភ្នែក(Scanning Reading)  ដោយមើលមួយត្រួសយ៉ាងលឿនទៅលើគោលដៅនៃអត្ថបទនិពន្ធ ដូចជា ប្រយោគសំខាន់ៗ តួអក្សរជិតៗ ឬសញ្ញាផ្សេងៗ ហើយអានលម្អិតចំពោះតែអ្វីដែលយើងចង់ដឹង ដូចជាអានដើម្បីស្វែងរកមើលពាក្យក្នុងវចនានុក្រមឬមើលផែនទីដូច្នោះ។

៤. អានចំណុចសំខាន់  អានរឿងរ៉ាវ អត្ថបទ ដោយស្វែងយល់ឱ្យជាក់លាក់ពីចំណុចសំខាន់  ដែលជាទូទៅច្រើនតែអានទៅលើអត្ថបទណាដែលមិនវែងហួសពេក។  ការអានឱ្យបានលឿន តែឱ្យច្រើនដង នឹងជួយឱ្យអាចចាប់យកចំណុចសំខាន់ៗដោយប្រើវិធីសង្កេតមើលពាក្យសំខាន់ៗ ប្រយោគ  ដែលមានសារៈសំខា ន់  ហើយបូកសរុបយកគំនិតសំខាន់ៗទុកសម្រាប់ប្រើ។

៥. អានសរុបខ្លឹមសារ      ជាការអានដែលអាចវាយតម្លៃបានយ៉ាងច្បាស់លាស់ពីខ្លឹមសារអត្ថបទ អាចបែងចែកផ្នែកសំខាន់និងមិនសំខាន់យ៉ាងល្អ ដឹងថាអ្វីជាការពិត អ្វីគ្រាន់តែជាទស្សនៈ?  អ្វីជាគំនិតសំខាន់  អ្វីជាគំនិតបន្ទាប់បន្សំ?ការអានសរុបមានលក្ខណៈពីរយ៉ាង  គឺសរុបទៅតាមទំព័រឬវគ្គ  ឬមួយសរុបតាមជំពូក  ឬសាច់រឿងទាំងមូលតែម្ដង។ការអានសរុបគួរតែធ្វើដោយត្រួសៗល្មមឱ្យដឹងសាច់រឿងខ្លះសិន ហើយអានលម្អិតម្ដងទៀតដើម្បីឱ្យយល់បានល្អ។ បន្ទាប់មកដាក់ជាសំណួរដល់ខ្លួនឯងអំពីអ្វីដែលបានអានមកថា  តើវាទាក់ទងនឹងអ្វីខ្លះ? មានដំណើររឿងដូចម្ដេច? ហើយរៀបរៀងខ្លឹមសារជាថ្មីតាមភាសារបស់ខ្លួនឡើងវិញ។

៦. អានវិភាគពិចារណា  ការអានដើម្បីស្រាវជ្រាវធ្វើរបាយការណ៍  ជាទូទៅតែងមានការវិភាគទៅលើខ្លឹមសារអត្ថបទ   ព្រោះអ្នកនិពន្ធអាចសរសេរដោយប្រើសំនួនភាសាទៅតាមបែបផ្សេងៗ អាចជាការប្រើភាសាត្រង់ៗ សាមញ្ញ ងាយយល់  ឬមួយជាភាសាដែលបង្កប់អត្ថន័យស៊ីជម្រៅ  ដែលតម្រូវឱ្យប្រើការគិត ដើម្បីស្វែងយល់ពីគោលបំណងអ្នកនិពន្ធឬគេអាចប្រើភាសាដែលជាការសម្ដែងមនោសញ្ចេតនាឬអារម្មណ៍របស់អ្នកនិពន្ធ។  អ្នកអានដែលមាន

ចំណេះដឹងជ្រៅជ្រះ ក្នុងការប្រើពាក្យពេចន៍និងសំនួនវោហារបានល្អ មានបទពិសោធនិងមានសតិក្នុងការអាន គឺពិតជាអាចវិភាគបានយ៉ាងត្រឹមត្រូវទៅលើអត្ថន័យ ដែលអ្នកនិពន្ធ ចង់បង្ហាញ ហើយអាចស្វែងយល់ពីអត្ថបទដែលអានបានយ៉ាងត្រឹមត្រូវ។

ហ្វ្រានស៊ីស បេកន ពោលថា "ការអានធ្វើឱ្យមនុស្សក្លាយជាមនុស្សពេញលក្ខណៈ" ការអានជាប្រការសំខាន់ចំពោះមនុស្ស ព្រោះមនុស្សមិនអាចក្លាយជាមនុស្សពេញលក្ខណៈបានទេ កាលបើពុំមានការអាន ដែលជាចំណែកមួយ នៃការប្រាស្រ័យទាក់ទងផ្នែកចំណេះដឹងខាងភាសា ដែលត្រូវហ្វឹកហាត់ជាប្រចាំហើយដែលអាចហ្វឹកហាត់បានជាបន្តបន្ទាប់តាមវ័យ និងតាមកម្រិតបទពិសោធដែលពុំមានថ្ងៃបញ្ចប់។

# មេរៀនទី ២

*នៅផ្ទះម្ដាយទីទៃ នៅព្រៃម្ដាយជាមួយ*

## អត្ថបទសំខាន់

### សិស្សជាប់ចំណាត់ថ្នាក់ក្រោយគេ



ឆ្នាំនេះ ផាន់ អាយុ ១១ ឆ្នាំហើយ។ ក្រោយពីឪពុកផាន់ទទួលអនិច្ចកម្មទៅ មីងសំបានបញ្ជូនផាន់ ដែលជាកូនប្រុសទោលរបស់គាត់ ទៅរៀននៅមជ្ឈមណ្ឌលអប់រំកុមារមួយ។

ផាន់តែងនឹកម្ដាយជានិច្ច ព្រោះតាំងពីតូចមក វាពុំដែបែកពីគ្រួសារសោះ។ពេលខ្លះ ផាន់ស្រមៃឃើញម្ដាយ រហូតភ្លេចស្ដាប់គ្រូពន្យល់។ នៅក្នុងថ្នាក់ ផាន់អង្គុយក្បែរក្មេងរប៉ិលរប៉ូចម្នាក់។ ក្មេងនេះ ចូលចិត្តនាំផាន់និយាយ ឬធ្វើអ្វីផ្សេងៗ នៅពេលកំពុងរៀន។

ច្រើនខែបានកន្លងផុតទៅ។ ការប្រកាសលទ្ធផលប្រចាំឆមាសមកដល់។ សិស្សម្នាក់ៗទន្ទឹងរង់ចាំលទ្ធផលសិក្សារបស់ខ្លួន ក្នុងអារម្មណ៍ភ័យផងអរផង។ អ្នកគ្រូហៅឈ្មោះសិស្សទាំងអស់ជាបន្តបន្ទាប់ លើកលែងតែឈ្មោះផាន់ប៉ុននោះ។ ពេលនោះផាន់នឹកក្នុងចិត្តថាប្រហែលជាអ្នកគ្រូហៅរំលងឈ្មោះខ្លួនហើយ។

ផាន់គិតមិនទាន់ចប់ផង ស្រាប់តែអ្នកគ្រូប្រកាសថា ឈ្មោះផាន់ជាប់ចំណាត់ថ្នាក់លេខ ៤០ ក្នុងចំណោមសិស្ស ៤០ នាក់។ ពេលនោះទឹកមុខផាន់ប្រែប្រួលខុសពីធម្មតា។ ផាន់

ក្ដុកក្ដួលផង ខ្មាសមិត្តភក្ដិផង ក៏ក្រាបក្បាលលើតុ ហើយពោលតិចៗ ៖ ម៉ែ! ឱម៉ែអើយ! ប្រសិនបើម៉ែដឹងថា ...។

ក្នុងចំណោមសិស្សទាំងអស់ មានសិស្សម្នាក់ដែលអង្គុយជាប់ខាងក្រោយផាន់ចាប់អារម្មណ៍លើអាកប្បកិរិយារបស់ផាន់។ សិស្សនោះយកក្រដាសតូចមួយសន្លឹកមកសរសេរ ហើយហុចឱ្យផាន់។ សំបុត្រនោះមានសេចក្ដីថា ៖ ផាន់! កុំយំសោកអ្វី។ ឯងត្រូវតាំងចិត្តឱ្យក្លាហានឡើង។ កាលពីឆ្នាំមុន ខ្ញុំក៏មានរឿងដូចឯងដែរ តែខ្ញុំមិនអស់សង្ឃឹម មិនយំដូចឯងទេ។ ផ្ទុយទៅវិញ ខ្ញុំប្រមូលអស់កម្លាំងកាយចិត្ត ខំរៀនសូត្រទ្វេមួយជាពីរ រហូតបានលទ្ធផលល្អដូចសព្វថ្ងៃនេះ។ ដូចនេះសូមមិត្តជូតទឹកភ្នែកចេញ ហើយតាំងចិត្តខំរៀនសូត្រសាជាថ្មី មិត្តនឹងបានសំរេចដូចបំណង។ ផាន់អានសំបុត្រដ៏មានខ្លឹមសារនេះចប់ ហាក់ដូចជាមានកម្លាំងចិត្តឡើងវិញ។ វាខំសំរួលអារម្មណ៍និងឥរិយាបថ ហើយងាកមុខមករកកែវ។ ទាំងពីរនាក់ញញឹមដាក់គ្នា។

តាំងពីពេលនោះមក ផាន់មានមិត្តដ៏ល្អម្នាក់។ ពេលទំនេរ កែវទៅជួយពន្យល់មេរៀននិងលំហាត់ដល់ផាន់ រីឯផាន់កាន់តែមានការកក់ក្ដៅឡើង ហើយខំរៀនសូត្រគ្រប់មុខវិជ្ជា។

មួយឆ្នាំកន្លងផុតទៅ ផាន់រៀនកាន់តែពូកែឡើងៗ រហូតបានជាប់លេខល្អដូចកែវទាយមែន។ ផាន់សប្បាយចិត្តណាស់ តែវាមានអារម្មណ៍មួយខ្លាចកែវអន់ចិត្ត។ ផ្ទុយទៅវិញ កែវបានបង្ហាញការរីករាយយ៉ាងខ្លាំងដោយខ្លួនបានជួយណែនាំមិត្តម្នាក់ឱ្យសំរេចបានជោគជ័យ។

## ពាក្យថ្មី

| | | | |
|---|---|---|---|
| អនិច្ចកម្ម | [巴；梵] | *ន.* | 逝世，死亡 |
| បញ្ជូន | [高] | *កិ.* | 送，运送，运输 |
| បែក | [高] | *កិ.* | 分离，分开 |
| ស្រមៃ | [高] | *កិ.* | 想象，幻想 |
| រពិលរប៉ូច | [高] | *គុ.* | 调皮的，淘气的 |
| ប្រចាំ | [高] | *កិ.* | 备用，常备 |



此为试读，需要完整PDF请访问：www.ertongbook.com